# “កុំចុះចាញ់នឹងព្រហ្មលិខិតត្រូវតស៊ូឡើង !”

## ស៊ិន សុជា ស្រ្តីវ័យ៤០ឆ្នាំ ដែលជាស្រ្តីមានពិការភាព រស់នៅខេត្តសៀមរាប ប្រទេសកម្ពុជា។




## អបអរសាទរទិវាសិទ្ធនារីអន្តរជាតិ #CHOOSETOCHALLENGE


សរសេរដោយ៖ ឃីម និង ឃ្លៃរ
ថតរូបដោយ៖ សោភា


**“ស្រ្តីមានពិការភាពក្នុងភាពជាអ្នកដឹកនាំ៖ ការសម្រេចបាននូវអនាគតដ៏ប្រសើរដូចគ្នានៅក្នុងសម័យកូវីត១៩”**

អបអរសាទរទិវាសិទ្ធនារីអន្តរជាតិ! ឆ្នាំនេះពួកយើងប្រារព្ធពិធីនេះឡើង **#choosetochallenge**ដើម្បីអបអរទៅដល់ស្រ្តីនិងកុមារីមានពិការភាពជុំវិញពិភពលោកសម្រាប់ភាពជាអ្នកដឹកនាំដ៏អស្ចារ្យរបស់ពួកគាត់ក្នុងសម័យកាលរីករាលដាលនៃវីរុសកូវីត១៩។

សហគ្រាសសង្គម អ៊ែលដ្យាល់បានជួបជាមួយបងស្រី ស៊ិន សុជា អាយុ៤០ឆ្នាំ
រស់នៅខេត្តសៀមរាបដែលបានចូលរួមក្នុងវគ្គបណ្តុះបណ្តាលអាជីវកម្ម
ពោធិព្រឹក្ស។

បងស្រីសុជាមានពិការភាពប្រភេទប៉ូលីយ៉ូដែលតម្រូវអោយគាត់ប្រើប្រាស់រទេះរុញ
ជាចាំបាច់។បច្ចុប្បន្នគាត់មានមុខរបរជាជាងកាត់ដេរប៉ុន្តែការរីករាលដាលនៃវីរុស
កូវីត ១៩បានធ្វើឲ្យមានផលប៉ះពាល់យ៉ាងខ្លាំងទៅដល់អាជីវកម្មរបស់គាត់
ដោយសារសាលារៀននិងរោងការត្រូវបានផ្អាក។ សព្វថ្ងៃនេះ បងស្រីសុជាបាន
បើកហាងកាត់ដេរដោយខ្លួនឯងនៅផ្ទះប៉ុន្តែគាត់បានជួបផលវិបាកមួយចំនួន
ដូចជាកង្វះថវិកា សម្ភារៈកាត់ដេរ ហើយការកាត់ដេររបស់គាត់ហើយមានល្បឿន
កំណត់បន្តិចដោយសារគាត់ប្រើតែដៃសម្រាប់ដេរនិងម៉ាស៊ីនដេរទៀតចុចម៉ូទ័រ។
ទោះជាយ៉ាងណាក៏ដោយ គាត់មានភាពជឿជាក់យ៉ាងមោះមុតថា
**“ថ្ងៃមុខទៅខ្ញុំនឹងជួយស្ត្រីដែលមានពិការភាពផ្សេងទៀតឲ្យមានការងារធ្វើដូច
ជាខ្ញុំដែរ”។** ថ្មីៗនេះគាត់កំពុងបង្រៀនស្ត្រីដែលមានពិការភាពពីររូបផ្សេងទៀត
ឲ្យចេះកាត់ដេរដូចគាត់ដែរដើម្បីឲ្យពួកគេមានជំនាញសម្រាប់ថ្ងៃអនាគតក្នុងការ
ប្រកបអាជីវកម្មផ្ទាល់ខ្លួន។

បងស្រីសុជាអ្នកដឹកនាំដែលយើងត្រូវទទួលស្គាល់។ ទោះបីបងស្រីទទួល
បានការគាំទ្រពីសហគមន៍មិនសូវពេញលេញគួបផ្សំជាមួយផលប៉ះពាល់ដែល
កំពុងកើតមានដោយសារជំងឺរាតត្បាតយ៉ាងនេះក្តី ក៏បងស្រីនៅតែបន្តជួយស្ត្រី
ដែលនៅជុំវិញខ្លួនគាត់។

គាត់បានផ្ញើសារមកកាន់ស្ត្រីដែលមានពិការភាពទាំងអស់ថា៖
**“កុំចុះចាញ់នឹងព្រហ្មលិខិតត្រូវតស៊ូឡើង”**
**“ទោះបីជាយើងមានពិការភាពក៏យើងអាចធ្វើបាន”**
**“ទោះបីជាយើងធ្វើមិនបានច្រើនក៏យើងអាចធ្វើបានតាមសមត្ថភាពដែល
យើងមាន”។ “យើងត្រូវក្លាហានឡើងដើម្បីអនាគតថ្ងៃខាងមុខ”។**